**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ ៥៧៩ សខប

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៥

# ប្រកាស

## ស្តីពី

## ការផ្ទេរបេសកកម្មមុខងារ នៃវិស័យសុខាភិបាល ជូនការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក គោលដៅ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញច្បាប់ ស្តីពីការ គ្រប់គ្រងលើការប្រកបវិជ្ជាជីវៈ ឯកជនក្នុងវិស័យ វេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០០

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល

-បានឃើញសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ

-បានឃើញប្រកាសលេខ ០០១៤ អបស/និអបស ចុះថ្ងៃទី ១៣ ខែ មករា ២០០៩ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌ ក្នុងការសុំបើក ឬ បិទ ឬសុំប្តូរទីតាំង នៃគ្រឹះស្ថានលក់ឱសថ

-បានឃើញប្រកាសលេខ ០៣៤ អបស/មព ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសក្នុងការសុំបើកឬបិទ សុំកែទ្រង់ទ្រាយ ឬប្តូរទីតាំង នៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន

-បានឃើញប្រកាសលេខ ៩២៨ ប្រក ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក ខណ្ឌគោលដៅ របស់ក្រសួងមហាផ្ទៃ

-បានឃើញសេចក្តីសម្រេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ សាកល្បងនៅស្រុកសៀមរាប ខេត្តសៀមរាប ស្រុកបាត់ដំបង ខេត្តបាត់ដំបង

-បានឃើញសេចក្តីសម្រេចលេខ ១៣២៩ សសរ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការកំណត់ក្រុងគោលដៅ នៃការពង្រីកការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ សម្រាប់អនុវត្តក្នុងឆ្នាំទីពីរ (២០១០-២០១១)

-បានឃើញសេចក្តីសម្រេចលេខ ២២៨៨ សសរ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ ស្តីពីការ កំណត់ក្រុងគោលដៅ នៃការពង្រីកការិយាល័យច្រកចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ សម្រាប់អនុវត្តក្នុងឆ្នាំទី៣ (២០១១-២០១២)

-បានឃើញលិខិតលេខ ៦៤ អ.ក.ម ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដោយមានចំណារឯកភាពរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីការផ្លាស់ប្តូរឈ្មោះ ស្រុក ខណ្ឌគោលដៅ នៃការពង្រីកការិយាល័យច្រកចេញចូលតែមួយ.

# សម្រេច

ប្រការ១.-

ត្រូវបានផ្ទេរប្រតិភូកម្មមុខងារ ពីក្រសួងសុខាភិបាល ជូនដល់ការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុកគោលដៅ ក្នុងការចេញលិខិតអនុញ្ញាត សុំបើក ឬ បិទ ឬ ប្តូរទីតាំង និង បន្តសុពលភាពសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ។

ប្រការ២.-

ការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុកគោលដៅ ដែលត្រូវទទួលមុខងារ ក្នុងការចេញលិខិតអនុញ្ញាត ដូចចែងក្នុងប្រការ ១ មាន ៖

| | |
|---|---|
| ១-ក្រុងសៀមរាប | នៃខេត្តសៀមរាប |
| ២-ក្រុងប៉ោយប៉ែត | នៃខេត្តបន្ទាយមានជ័យ |
| ៣-ក្រុងបាត់ដំបង | នៃខេត្តបាត់ដំបង |
| ៤-ក្រុងពោធិ៍សាត់ | នៃខេត្តពោធិ៍សាត់ |
| ៥-ក្រុងកំពង់ឆ្នាំង | នៃខេត្តកំពង់ឆ្នាំង |
| ៦-ក្រុងច្បារមន | នៃខេត្តកំពង់ស្ពឺ |
| ៧-ក្រុងតាខ្មៅ | នៃខេត្តកណ្តាល |
| ៨-ក្រុងស្ទឹងសែន | នៃខេត្តកំពង់ធំ |
| ៩-ក្រុងសួង | នៃខេត្តកំពង់ចាម |
| ១០-ក្រុងក្រចេះ | នៃខេត្តក្រចេះ |
| ១១-ក្រុងបានលុង | នៃខេត្តរតនគិរី |
| ១២-ក្រុងបាវិត | នៃខេត្តស្វាយរៀង |
| ១៣-ក្រុងកំពត | នៃខេត្តកំពត |
| ១៤-ក្រុងដូនកែវ | នៃខេត្តតាកែវ |
| ១៥-ក្រុងព្រះសីហនុ | នៃខេត្តព្រះសីហនុ |
| ១៦-ក្រុងខេមរភូមិន្ទ | នៃខេត្តកោះកុង |
| ១៧-ស្រុកពាមរក៍ | នៃខេត្តព្រៃវែង |
| ១៨-ក្រុងសែនមនោរម្យ | នៃខេត្តមណ្ឌលគិរី |
| ១៩-ក្រុងស្ទឹងត្រែង | នៃខេត្តស្ទឹងត្រែង |
| ២០-ក្រុងសំរោង | នៃខេត្តឧត្តរមានជ័យ |
| ២១-ក្រុងព្រះវិហារ | នៃខេត្តព្រះវិហារ |
| ២២-ក្រុងប៉ៃលិន | នៃខេត្តប៉ៃលិន |
| ២៣-ក្រុងកែប | នៃខេត្តកែប ។ |

ប្រការ៣.-

សេវាឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលត្រូវផ្ទេរប្រតិភូកម្មជូនការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុកគោលដៅ ក្នុងការចេញលិខិតអនុញ្ញាត មាន ៖

-បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះមុននិងក្រោយសម្រាល គ្រប់គ្រងដោយឆ្មប ដែលមានកំរិតបរិញ្ញាបត្ររងឆ្មប ឬ សញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

-បន្ទប់ព្យាបាលដោយចលនា គ្រប់គ្រងដោយ អ្នកព្យាបាលដោយចលនា ដែលមានកំរិត បរិញ្ញាបត្ររងព្យាបាលដោយចលនា ឬ សញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

-បន្ទប់ថែទាំជំងឺ គ្រប់គ្រងដោយគិលានុបដ្ឋាក ដែលមានកំរិត បរិញ្ញាបត្ររងគិលានុបដ្ឋាក ឬ សញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

-ឱសថស្ថានរង គ្រប់គ្រងដោយ ឱសថការីមធ្យម ដែលមានសញ្ញាបត្រ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

ប្រការ៤.-

មន្ត្រីទទួលបន្ទុកបច្ចេកទេសសុខាភិបាល ត្រូវរៀបចំគំរូបែបបទផ្សេងៗ រួមទាំងឯកសារពាក់ព័ន្ធ សម្រាប់ការចេញលិខិតអនុញ្ញាតទៅតាមប្រភេទសេវាសុខាភិបាលដូចចែងក្នុងប្រការ៣ ។

ប្រការ៥.-

ការអនុវត្តលើគំរូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត របស់ការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុកគោលដៅ របស់មន្ត្រីជំនួយការ អភិបាលក្រុង ស្រុកគោលដៅ ត្រូវកំណត់ដោយសេចក្តីណែនាំមួយដោយឡែក របស់ក្រសួងសុខាភិបាល ។

ប្រការ៦.-

សាលាក្រុង ស្រុកគោលដៅ មានការិយាល័យច្រកចេញចូលតែមួយ ត្រូវផ្ញើលិខិតចម្លង ស្តីពីការផ្តល់លិខិតអនុញ្ញាត ដូចចែងក្នុងប្រការ១ និង ផ្តល់របាយការណ៍ស្ថិតិ ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ មកក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ប្រការ៧.-

ប្រកាសលេខ២៥៥ សន.ប ចុះថ្ងៃទី២៦ខែធ្នូ ឆ្នាំ២០១១ ស្តីពីការផ្ទេរប្រតិភូកម្មមុខងារនៃវិស័យសុខាភិបាលជូនការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក គោលដៅ ត្រូវបានទុកជានិរាករណ៍ ។

ប្រការ៨.-

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលខេត្តពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ

ម៉ម-ប៊ុនហេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ...២០៦...សនប

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១២

# សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តប្រកាសលេខ ៥២៨ ស.ណប ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ របស់ក្រសួងសុខាភិបាល ស្តីពី ការធ្វើប្រតិភូកម្មមុខងារ នៃវិស័យសុខាភិបាលជូនការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក គោលដៅ

ដើម្បីលើកកំពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រព័ន្ធរដ្ឋបាល ដោយពង្រីកវិសាលភាពសេវាកម្ម ដែលផ្តល់ដោយរដ្ឋបាល ក្រុង ស្រុក ឲ្យបានទូលំ ទូលាយ តាមរយៈការប្រមូលផ្តុំ សេវាកម្មទាំងអស់ក្នុងក្របខណ្ឌសមត្ថកិច្ចនៅច្រកចេញចូលតែមួយ ក្នុងគោលបំណងបម្រើប្រជាពលរដ្ឋ ឲ្យមានប្រសិទ្ធភាព ហើយប្រើប្រាស់ធនធាន ដែលមានស្រាប់នៅថ្នាក់ ក្រុង ស្រុក ទៅតាមនីតិវិធីរដ្ឋបាល ក្រសួងសុខាភិបាល សូមណែនាំការអនុវត្តទម្រង់ បែបបទ និងឯកសារគំរូសម្រាប់មន្ត្រី ដែលបំពេញការងារនៅ ការិយាល័យច្រកចេញចូលតែមួយ ដូចខាងក្រោម:

1. អំពីអ្នកគ្រប់គ្រង ឬ អ្នកផ្តល់សេវាបែបបទ និងលក្ខខណ្ឌបច្ចេកទេស ក្នុងការសុំបើក ឬផ្លាស់ប្តូរទីតាំង ឬ បន្ត អ្នកផ្តល់សេវា (ឧបសម្ព័ន្ធ ១):

១. អ្នកគ្រប់គ្រង ឬ អ្នកផ្តល់សេវា:

- ត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានសុខភាពល្អ អាចបម្រើការងារបាន
- បានចុះឈ្មោះជាសមាជិក គណៈវិជ្ជាជីវៈនីមួយៗ
- ត្រូវមានសញ្ញាបត្រ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬ សញ្ញាបត្រប្រហាក់ប្រហែលដែលទទួលស្គាល់ដោយ ក្រសួងអប់រំយុវជន និងកីឡា ឬ គណៈកម្មាធិការពិនិត្យវាយតម្លៃកំរិតសញ្ញាបត្រ នៃកម្ពុជា
- អ្នកគ្រប់គ្រង ឬ អ្នកផ្តល់សេវា មិនអនុញ្ញាតឲ្យមានអ្នកជំនួសឡើយ ។

២. បែបបទនិងលក្ខខណ្ឌបច្ចេកទេសក្នុងការសុំបើក ឬ ផ្លាស់ប្តូរទីតាំងឬ បន្តសុពលភាពសេវា:

ក/ បែបបទសុំបើកសេវាបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ព្យាបាលដោយចលនា បន្ទប់ ថែទាំជម្ងឺ និងឱសថស្ថានរង ត្រូវមាន:

១- ពាក្យសុំបើកសេវា "មានគំរូ" មានបិទតែមប្រឹ៍១០០០ រៀល 01 ច្បាប់

២- ជីវប្រវត្តិសង្ខេបរបស់សាមីជន "មានគំរូ" 01 ច្បាប់

៣- កិច្ចសន្យារបស់សាមីជន "មានគំរូ" 01 ច្បាប់

៤- វិញ្ញាបនបត្រសុខភាព ចេញដោយក្រសួងសុខាភិបាល ឬ មន្ទីរពេទ្យរដ្ឋ 01 ច្បាប់

៥- គំនូសបំព្រួញទីតាំងដោយមានបញ្ជាក់ពី ឃុំ/ សង្កាត់ 01 ច្បាប់

៦- មានកំរិតបរិញ្ញាបត្ររង ឬ សញ្ញាបត្រ គិលានុបដ្ឋាក ព្យាបាលដោយចលនា ឱសថការីមធ្យម ឬ សញ្ញាបត្រសមមូល ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬ ក្រសួងអប់រំយុវជន និងកីឡា ឬ គណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាបត្រ និង បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម បញ្ជាក់ពីសាលារាជធានី-ខេត្ត 01 ច្បាប់

៧. លិខិតបញ្ជាក់ថាបានចុះឈ្មោះក្នុងគណៈវិជ្ជាជីវៈ 01 ច្បាប់

៨. រូបថតសាមីជន (បច្ចុប្បន្ន) ៤×៦ស.ម ចំនួន 0៧ សន្លឹក

៩. លិខិតថ្កោលទោស ចំពោះអ្នកមិនបម្រើការងាររដ្ឋ 01 ច្បាប់

ខ/ បែបបទ សុំផ្លាស់ប្តូរទីតាំងសេវា បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ព្យាបាលដោយចលនា បន្ទប់ថែទាំជម្ងឺ និងឱសថស្ថានរង ត្រូវមាន:

១. ពាក្យសុំប្តូរទីតាំងថ្មី "មានគំរូ" មានបិទតែមប្រ៊ិ ១០០០ រៀល 01 ច្បាប់

២. លិខិតអនុញ្ញាតចាស់ "ច្បាប់ដើម" 01 ច្បាប់

៣. កិច្ចសន្យារបស់សាមីជន "មានគំរូ" 01 ច្បាប់

៤. គំនូសបំព្រួញទីតាំងថ្មី 01 ច្បាប់

៥. លក្ខណៈវិនិច្ឆ័យបន្ទប់ពិគ្រោះ ឬ ទីតាំងឱសថស្ថានរង 01 ច្បាប់

៦. របាយការណ៍ សកម្មភាពកន្លងមក 01 ច្បាប់

៧. រូបថតសាមីជន (បច្ចុប្បន្ន) ៤×៦ ស.ម ចំនួន 0៧ សន្លឹក

គ/ បែបបទ សុំបន្តសុពលភាពសេវា បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ព្យាបាលដោយចលនា បន្ទប់ថែទាំជម្ងឺ និងឱសថស្ថានរងត្រូវមាន:

១. ពាក្យសុំបន្តសុពលភាពសេវាវេជ្ជសាស្ត្រ "មានគំរូ" មានបិទតែមប្រ៊ិ ១០០០រៀល 01 ច្បាប់

២. លិខិតអនុញ្ញាតដែលការិយាល័យច្រកចេញចូលតែមួយ ចេញឲ្យ លេខ.................... ចុះថ្ងៃទី......... ខែ............ ឆ្នាំ............ 01 ច្បាប់

៣. កិច្ចសន្យា 01 ច្បាប់

៣. កិច្ចសន្យា ០១ ច្បាប់

៤. គំនូសបំព្រួញទីតាំង ០១ ច្បាប់

៥. លក្ខណៈវិនិច្ឆ័យបន្ទប់ពិគ្រោះ ឬ ទីតាំងឱសថស្ថានរង ០១ ច្បាប់

៦. របាយការណ៍ ស្តីពីការរៀបចំសកម្មភាពសេវាកម្ម ក្នុងរយៈពេលកន្លងមក និង គម្រោងរៀបចំសេវាកម្មបន្ត ០១ ច្បាប់

៧. បង្កាន់ដៃដាក់ពាក្យសុំបើកសេវាវេជ្ជសាស្ត្រ ០១ ច្បាប់

៨. រូបថតសាមីជន (បច្ចុប្បន្ន) ៤×៦ស.ម ចំនួន ០៣ សន្លឹក

៩. ថតរូបចំពីមុខទីតាំងបើកទំហំ ១៥× ២០ ០១ សន្លឹក

**ឃ/** លក្ខខណ្ឌបច្ចេកទេស សុំបើកសេវា បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះបន្ទប់ព្យាបាលដោយចលនា បន្ទប់ថែទាំជម្ងឺ និងឱសថស្ថានរង:

១. បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ

អាចបើកបន្ទប់ពិគ្រោះ ស្ត្រីមានផ្ទៃពោះ បានចំពោះតែ ឆ្មប ដែលមានកំរិតបរិញ្ញាបត្ររង ឆ្មប ឬ សញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល និងបានចុះឈ្មោះ ជាសមាជិកគណៈឆ្មប ហើយត្រូវគោរពលក្ខខណ្ឌដូចខាងក្រោម:

- មានស្លាកសញ្ញា បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះត្រឹមត្រូវ ដែលកំណត់ដោយសេចក្តីណែនាំរបស់ការិយាល័យច្រកចេញចូលតែមួយ
- មានកន្លែងរង់ចាំ ដែលមានទំហំយ៉ាងតូច ៨ម² និងមានកៅអី ឬ សាឡុងសម្រាប់រង់ចាំ
- មានសៀវភៅ សម្រាប់កត់ត្រាពីសកម្មភាព នៃការពិគ្រោះស្ត្រីមានផ្ទៃពោះប្រចាំថ្ងៃ
- មានបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ ដែលមានទំហំយ៉ាងតូច ១២ម²
- មានគ្រែយ៉ាងច្រើនបំផុត២ សម្រាប់ធ្វើការពិគ្រោះ និងថែទាំ
- មានតារាងតម្លៃពិគ្រោះព្យាបាលជម្ងឺ
- មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ (បើមាន)
- មានឧបករណ៍រំងាប់មេរោគ
- មានធុងសំរាម
- មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ សំណល់ឆ្លងរោគ និងមានកន្តោរ
- ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជម្ងឺរៀងរាល់បីខែ (០៣ខែ) ម្តងផ្ញើមក
- ការិយាល័យច្រកចេញចូលតែមួយ រួចបញ្ជូនមកមន្ទីរសុខាភិបាលរាជធានី - ខេត្ត

* បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះធ្វើការងារ:

- ផ្តល់ការថែទាំមុន និងក្រោយសំរាល
- ពិនិត្យផ្ទៃពោះ
- អប់រំសុខភាព
- ចាក់ថ្នាំបង្ការមុន និងក្រោយសំរាល
-អាចផ្តល់ឱសថជូនស្ត្រីមានផ្ទៃពោះ ទៅតាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិតតែប៉ុណ្ណោះ
- មានទូ១ ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជម្ងឺ-បរិក្ខារពេទ្យប្រើប្រាស់សមស្រប
- ហាមធ្វើការរំលូតកូន និងសម្រាលកូនក្នុងបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ
- មិនអនុញ្ញាតដាក់តាំងលក់ឱសថ ក្នុងបន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ ជាដាច់ ខាត
- ម្ចាស់សេវាត្រូវមានសំលៀកបំពាក់ ឯកសណ្ឋានពេទ្យ មានប៉ាក់ឈ្មោះត្រឹម ត្រូវ ។

២. បន្ទប់ព្យាបាលដោយចលនា:

អាចបើកបន្ទប់ព្យាលបាលដោយចលនា បានចំពោះតែ អ្នកព្យាបាលដោយចលនា ដែលមានកំរិតបរិញ្ញាបត្ររង ព្យាបាលដោយចលនា ឬ សញ្ញាបត្រសមមូល ឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយត្រូវគោរពលក្ខខណ្ឌដូចខាងក្រោមនេះ៖

- មានស្លាកសញ្ញាជាបន្ទប់ ព្យាបាលដោយចលនាត្រឹមត្រូវដែលបានកំណត់ដោយ សេចក្តីណែនាំរបស់ការិយាល័យច្រកចេញចូលតែមួយ
-មានកន្លែងរងចាំដែលមានទំហំយ៉ាងតូច ៨ម² និងមានកៅអី ឬ សាឡុង សម្រាប់រងចាំ
- មានសៀវភៅសម្រាប់កត់ត្រាជម្ងឺប្រចាំថ្ងៃ
- មានបន្ទប់ព្យាបាលដោយចលនាដែលមានទំហំយ៉ាងតូច ១២ម²
- មានគ្រែយ៉ាងច្រើនបំផុតចំនួន ២
- មានតារាងតម្លៃព្យាបាលជម្ងឺ
- មានឡាវ៉ាបូនិងសាប៊ូសម្រាប់លាងដៃ
- មានធុងសំរាម
- ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពព្យាបាលជម្ងឺរៀងរាល់បីខែ (០៣ខែ) ម្តងផ្ញើមក
- ការិយាល័យច្រកចេញចូលតែមួយរួចបញ្ជូនមក មន្ទីរសុខាភិបាលរាជធានី - ខេត្ត

* អ្នកព្យាបាលដោយចលនាធ្វើការងារ:

-ព្យាបាលដោយចលនាតាមវេជ្ជបញ្ជាគ្រូពេទ្យ ដើម្បីស្តារលទ្ធភាពពលកម្មជនរងគ្រោះនិងជនពិការ
- រាល់សម្ភារៈចាំបាច់សម្រាប់បម្រើការឲ្យសេវាកម្មនេះត្រូវធ្វើឡើងសមស្របទៅតាម ស្តង់ដារនិងត្រូវរក្សាសុវត្ថិភាពដល់អ្នកជម្ងឺក្នុងពេលប្រើប្រាស់

-ត្រូវមានការទំនាក់ទំនងប្រឹក្សាយោបល់ជាមួយគ្រូពេទ្យ ផ្នែកវេជ្ជសាស្ត្រ សល្យសាស្ត្រ និងផ្នែកពាក់ព័ន្ធដទៃទៀតដើម្បីឲ្យមានប្រសិទ្ធភាពការព្យាបាល

-ត្រូវគោរពសិទ្ធិអ្នកជម្ងឺជាមូលដ្ឋាន និងត្រូវផ្តល់ព័ត៌មានជាមុនដល់អ្នកជម្ងឺអំពីរបៀបព្យាបាល

-ត្រូវធ្វើការព្យាបាលក្នុងបរិយាកាសមួយដែលមានសុវត្ថិភាព ដល់អ្នកជម្ងឺព្រមទាំងផ្តល់ការប្រឹក្សាដល់អ្នកជម្ងឺ

- មានទូ១ ដាក់ឱសថនៅក្នុងបន្ទប់ពិនិត្យជម្ងឺ-បរិក្ខារពេទ្យប្រើប្រាស់សមស្រប

- ហាមធ្វើការព្យាបាលដោយពុំសមស្របក្រៅពីសមត្ថភាពចំណេះដឹងរបស់ខ្លួន

- មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ពិគ្រោះព្យាបាលជម្ងឺជាដាច់ខាត ។

៣/ បន្ទប់ថែទាំជម្ងឺ:

អាចបើកបន្ទប់ថែទាំជម្ងឺបានចំពោះតែ គិលានុបដ្ឋាកដែលមានកំរិតបរិញ្ញាបត្ររង គិលានុបដ្ឋាកឬសញ្ញាបត្រសមមូលឡើងទៅទទួលស្គាល់ដោយ ក្រសួងសុខាភិបាលហើយត្រូវគោរពលក្ខខណ្ឌដូចខាងក្រោមនេះ ៖

- មានស្លាកសញ្ញា ជាបន្ទប់ថែទាំជម្ងឺត្រឹមត្រូវដែលបានកំណត់ដោយសេចក្តីណែនាំរបស់ការិយាល័យច្រកចេញចូលតែមួយ

- មានកន្លែងរង់ចាំដែលមានទំហំយ៉ាងតូច ៨ម² និងមានកៅអី ឬ សាឡុងសម្រាប់រង់ចាំ

- មានសៀវភៅសម្រាប់កត់ត្រាពីសកម្មភាព នៃការថែទាំជម្ងឺប្រចាំថ្ងៃ

- មានបន្ទប់ថែទាំជម្ងឺដែលមានទំហំយ៉ាងតិច ១២ម²

- មានគ្រែយ៉ាងច្រើនបំផុត ចំនួន ២

- មានតារាងតម្លៃព្យាបាលជម្ងឺ

- មានឡាវ៉ាបូ និងសាប៊ូសម្រាប់លាងដៃ

- មានឧបករណ៍រំងាប់មេរោគ

- មានធុងសំរាម

- មានប្រអប់សុវត្ថិភាពសម្រាប់ដាក់វត្ថុមុតស្រួច និងធុងសំរាមសម្រាប់ដាក់សំណល់ទូទៅ សំណល់ឆ្លងរោគ និងមានកន្ត្រៃ ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពថែទាំជម្ងឺរៀងរាល់បីខែ (០៣ខែ) ម្តងផ្ញើ មកការិយាល័យច្រកចេញចូលតែមួយ រួចបញ្ជូនមកមន្ទីរសុខាភិបាលរាជធានី - ខេត្ត

* បន្ទប់ថែទាំជម្ងឺធ្វើការងារ:

-ថែទាំអ្នកជម្ងឺតាមវេជ្ជបញ្ជា

-លាងសំអាតរុំរបួសជូនអ្នកជម្ងឺ

- ផ្តល់ឱសថតាមវេជ្ជបញ្ជា
- តាមដានការវិវត្តន៍ជម្ងឺ ដើម្បីធ្វើការបញ្ជូនបន្តទៅសេវាទទួលខុសត្រូវក្នុងការព្យាបាល
- ត្រូវមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្រូពេទ្យ
- អនុវត្តការថែទាំជម្ងឺ ទៅតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល
- មានទូ១ដាក់ឱសថនៅក្នុងបន្ទប់ថែទាំជម្ងឺ-បរិក្ខារពេទ្យប្រើប្រាស់សមស្រប
- មិនអនុញ្ញាតដាក់តាំងលក់ឱសថក្នុងបន្ទប់ថែទាំជម្ងឺជាដាច់ខាត
- សំលៀកបំពាក់ឯកសណ្ឋានមានបាក់ឈ្មោះ ។

៤/ ឱសថស្ថានរង:

អាចបើកឱសថស្ថានរងបាន ចំពោះតែឱសថការីមធ្យម ដែលមានសញ្ញាបត្រទទួលស្គាល់ដោយក្រសួងសុខាភិបាល និងបានចុះឈ្មោះជាសមាជិកគណៈឱសថការី ហើយត្រូវបានគោរព លក្ខខណ្ឌដូចខាងក្រោម:

- បន្ទប់តាំងលក់ឱសថត្រូវមានផ្ទៃក្រឡាយ៉ាងតូច ១៦ម²
- មានស្លាកសញ្ញាឱសថស្ថានរង ដែលមានពណ៌ស អក្សរពណ៌ទឹកប៊ិច ទំហំ0,៦ × ៣,៨ ម៉ែត
- ហាមផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់រូបភាពលើស្លាកសញ្ញាឱសថស្ថានរង
- មានទូកញ្ចក់ស្អាតបាតពណ៌សសម្រាប់តាំងឱសថបរិក្ខារពេទ្យ
- មានទូបញ្ជរសម្រាប់បេឡាការីនិងអ្នកប្រគល់ឱសថ
- មានទូថ្នាំពិសេសសម្រាប់ដាក់ថ្នាំប្រព័ន្ធសរសៃប្រសាទ
- មានទូទឹកកកសម្រាប់ស្តុកឱសថដែលទាមទារការទុកដាក់ក្នុងសីតុណ្ហភាពកំណត់
- មានជញ្ជីងសម្រាប់ថ្លឹងទម្ងន់
- មានបន្ទប់ឲ្យឱសថប្រសិនបើមានត្រូវរៀបចំឲ្យបានសមស្របតាមបច្ចេកទេស។

* ឱសថស្ថានរង អាចតាំងលក់នូវប្រភេទឱសថដូចមានខាងក្រោម:

- ឱសថសម្រាប់វិស័យសុខាភិបាល
- ផលិតផលអនាម័យខ្លួនមនុស្ស ដែលមានគុណភាព
- សម្ភារៈបរិក្ខារពេទ្យខ្លះៗ
- អាចលក់រាយ តាមបញ្ជីកំណត់របស់ក្រសួង យោងសេចក្តីជូនដំណឹងលេខ ០៧៨ អបស/ឱអបស ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១០

- ត្រូវទិញឱសថ ពីឱសថស្ថាន ។

* បែបបទពាណិជ្ជកម្ម:

- ក្នុងឱសថស្ថានរង ត្រូវមានវត្តមាន របស់អ្នកទទួលខុសត្រូវ ជាឱសថការីមធ្យម
- អ្នកលក់ត្រូវពាក់អាវពេទ្យពណ៌ស និងមានពាក់ស្លាកឈ្មោះ
- ត្រូវចុះឈ្មោះឱសថ ដែលបានផ្តល់ជូន អតិថិជនក្នុងសៀវភៅស្រង់វេជ្ជបញ្ជា
- នៅពេលផ្តល់ឱសថរួចហើយ ត្រូវពិនិត្យឲ្យបានច្បាស់អំពីឈ្មោះ និងហត្ថលេខារបស់គ្រូពេទ្យ
- នៅលើវេជ្ជបញ្ជា ដែលផ្តល់ឱសថរួចហើយ ត្រូវបោះត្រាឱសថស្ថានរង និងមានឈ្មោះកាលបរិច្ឆេទលក់ឱសថ
- អ្នកលក់ឱសថ ត្រូវចេះអានហើយអាចសរសេរ ចេះបកស្រាយវេជ្ជបញ្ជា និងបរិយាយប័ណ្ណឱសថ ។

* ករណីត្រូវហាមឃាត់:

- ការតាំងលក់ឱសថ ដែលមានប្រភពមិនច្បាស់លាស់ ( ឱសថរត់ពន្ធ និង ឱសថខុសច្បាប់)
- ការតាំងលក់ឱសថ ដែលគ្មាន លតប័ត្រ (Vignette)
- ការតាំងលក់ឱសថ ដែលក្រសួងហាមឃាត់
- ការតាំងលក់ឱសថ ដែលផុតកំណត់ប្រើប្រាស់
- ការប្រកបរអាជីវកម្មផ្សេងទៀត ក្នុងឱសថស្ថានរង ។

**II.**អំពីតារាងតម្លៃសេវា និងសំណុំឯកសារគំរូពាក់ព័ន្ធ (ឧបសម្ព័ន្ធ ២):

១/តម្លៃ នៃការចេញលិខិតអនុញ្ញាតបើក ផ្លាស់ប្តូរ បន្តសុពលភាពសេវាវេជ្ជសាស្ត្រនិងឱសថស្ថានរង:

| ល.រ | ប្រភេទសេវា | តម្លៃស្របច្បាប់ | តម្លៃរក្សាទុក ៩០% | តម្លៃបង់ចូលរដ្ឋ១០% | រយៈពេលនៃការចេញលិខិតអនុញ្ញាត | សុពលភាព |
|---|---|---|---|---|---|---|
| ១ | សុំបើក បន្តសុពលភាព ប្តូរទីតាំង បន្ទប់ពិគ្រោះ ស្ត្រីមានផ្ទៃពោះ | 100 $ | 90 $ | 10 $ | ៧-១៥ ថ្ងៃ | រយៈពេល ៣ឆ្នាំ |
| ២ | សុំបើក បន្តសុពលភាព ប្តូរទីតាំង បន្ទប់ព្យាបាល ដោយចលនា | 100 $ | 90 $ | 10 $ | ៧-១៥ ថ្ងៃ | រយៈពេល ៣ឆ្នាំ |
| ៣ | សុំបើក បន្តសុពលភាព ប្តូរទីតាំង បន្ទប់ថែទាំធ្មេញ | 100 $ | 90 $ | 10 $ | ៧-១៥ ថ្ងៃ | រយៈពេល ៣ឆ្នាំ |
| ៤ | សុំបើក បន្តសុពលភាព ប្តូរទីតាំង ឱសថស្ថានរង | 100 $ | 90 $ | 10 $ | ៧-១៥ ថ្ងៃ | រយៈពេល ២ឆ្នាំ |

២/ សំណុំឯកសារគំរូពាក់ព័ន្ធ:

- ពាក្យសុំបើកសេវាវេជ្ជសាស្ត្រ និងឱសថស្ថានរង
- ពាក្យសុំប្តូរទីតាំងសេវាវេជ្ជសាស្ត្រ និងឱសថស្ថានរង
- ពាក្យសុំបន្តសុពលភាពសេវាវេជ្ជសាស្ត្រ និងឱសថស្ថានរង ។

ក្រសួងសុខាភិបាល សង្ឃឹម និងជឿជាក់ថា ក្រោយពេលទទួលបានសេចក្តីណែនាំនេះ លោកអភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ គោលដៅ មន្ត្រីរាជការទទួលខុសត្រូវគ្រប់លំដាប់ថ្នាក់ នៃក្រុង ស្រុក ខណ្ឌ គោលដៅ រួមជាមួយអតិថិជន និងអនុវត្តតាមនីតិវិធីខាងលើនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ការិយាល័យច្រកចេញចូលតែមួយ ក្រុង ស្រុក គោលដៅ
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត ដើម្បីសហការ
- ឯកសារ-កាលប្បវត្តិ

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

វេជ្ជ. ថែ គុយសាង